# អនុវិទ្យាល័យ ឃើណៃ

## កម្មវិធីសិក្សាសម្រាប់និស្សិតអន្តរជាតិ

**វិចតូរីយ៉ា, ប្រទេសអូស្ត្រាលី**

នាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល

Kurnai College
PATHWAYS TO SUCCESS



VICTORIA
State Government
Australia



នៅ អនុវិទ្យា ល័យ ឃីណៃ យើ ងផ្តល់តម្លៃ នូវ ទេ ពកោ សល្យ និងកម្រិ តសិក្សា របស់បុគ្គលនី មួយៗ។នេះ គឺជាការទទួលស្គាល់ថា សិស្ស ម្នា ក់ៗគឺខុសពីគ្នាដូច្នេះ ហើ យយើ ងនឹងជួយជំរុញ បុគ្គលនីមួយៗពីចំណុចចាប់ផ្តើ មដែ លស្រ បទៅ នឹងពួកគេ ផ្ទាល់។

# សារពីនាយកសាលា

អនុវិទ្យាល័យ ឃីណៃ គឺជាអនុវិទ្យាល័យមួយដែលត្រៀមនឹងស្វាគមន៍អ្នកជានិច្ចក្នុងការបន្តដំណើរសិក្សារបស់អ្នក។

ក្នុងនាមជានាយកសាលាម្នាក់ ខ្ញុំចង់ណែនាំខ្លួនឯងបន្តិច។ ឈ្មោះរបស់ខ្ញុំគឺ អាន់តូនី រ៉ូដាហាន់ ហើយខ្ញុំរស់នៅជាយក្រុងមួយឈ្មោះ យ៉ារ៉ាម ជាមួយប្រពន្ធខ្ញុំ ជេនណា ។ពួកយើងរស់នៅជាមួយកូនបីនាក់ ព្រមទាំងសត្វចិញ្ចឹមឆ្កែ និងផ្ទះរបស់យើងផងដែរ។ កន្លែងដែលគ្រួសាររបស់ខ្ញុំស្ថិតនៅចម្ងាយប្រហែល 30 នាទីពីអនុវិទ្យាល័យ ឃីណៃ និងនៅជិតឆ្នេរសមុទ្រ។

ជារៀងរាល់ឆមាស គ្រួសាររបស់ខ្ញុំតែងតែអញ្ជើញនិស្សិតអន្តរជាតិទាំងអស់មកលេងផ្ទះរបស់ខ្ញុំដើម្បី បរិភោគអាហារថ្ងៃត្រង់ ហើយក្នុងឱកាសនោះផងដែរ ខ្ញុំនឹងបង្ហាញអ្នកនិងសិស្សថ្មីផ្សេងទៀតរបស់យើងអំពីផ្ទះរបស់ខ្ញុំ និងតំបន់នៅជុំវិញ ។

ពួកយើងរស់នៅជាយក្រុងមួយដ៏ស្រស់ស្អាតបំផុតនៃប្រទេសអូស្រ្តាលី ហើយខ្ញុំពិតជារំភើបណាស់ក្នុងការបង្ហាញ អ្នកទាំងអស់គ្នាពីទីក្រុងរបស់យើង ព្រមទាំងជួយ ផ្តល់ការណែនាំ និងជំនួយដល់អ្នកក្នុងការធ្វើការសម្រេចចិត្តនូវផ្លូវដែលអ្នកបានជ្រើសរើសនាពេលអនាគត។

នៅអនុវិទ្យាល័យ ឃីណៃ អ្នកនឹងត្រូវបានមើលថែទាំយ៉ាងល្អពីបុគ្គលិករបស់យើងរួមមានអ្នកសម្របសម្រួល និស្សិតអន្តរជាតិដែលមានបទពិសោធន៍ជាច្រើនឆ្នាំរបស់យើង និងបុគ្គលិកផ្សេងទៀតដែលអាចនិយាយ ច្រើនភាសារួមមាន ចិន ជប៉ុន វៀតណាម និងអាល្លឺម៉ង់។

រាល់សិស្សានុសិស្សរបស់យើងមានសិទ្ធិចូលប្រើប្រាស់សម្ភារៈបរិក្ខារទាំងអស់ដែលផ្តល់ជូននៅ សាកលវិទ្យាល័យ Federation រួមទាំងទទួលបាននូវការបង្រៀនដោយឥតគិតថ្លៃពីនិស្សិតសាកលវិទ្យាល័យផ្សេងៗផងដែរ។ ម្យ៉ាងវិញទៀត អនុវិទ្យាល័យ ឃីណៃ យើងក៏មានក្បួរបោះជំរុំ និងដំណើរកំសាន្តដោយឥតគិតថ្លៃដែលរួមមាន ការធ្វើដំណើរទៅតាមរដ្ឋផ្សេងៗក្នុងប្រទេសអូស្រ្តាលីសម្រាប់និស្សិតអន្តរជាតិផងដែរ។

ក្នុងឆ្នាំកន្លងទៅ និស្សិតអន្តរជាតិជាច្រើនបានចូលរៀននៅអនុវិទ្យាល័យរបស់យើង ហើយពួកគេទទួលបានភាព ជោគជ័យនិងអស្ចារ្យជាច្រើន។ ជាចុងក្រោយ ខ្ញុំសង្ឃឹមថាដំណើរសិក្សារបស់អ្នកនឹងទទួលបានភាពជោគជ័យដូចពួកគេ។

**ពីខ្ញុំ**
**អាន់តូនី រ៉ូដាហាន់, នាយកសាលាអនុវិទ្យាល័យ ឃីណៃ**



# ហេតុអ្វីទៅត្រូវជ្រើសរើសមហាវិទ្យាល័យឃើណៃ?

**អនុវិទ្យាល័យ ឃើណៃ គឺជាសាលាដ៏ល្អបំផុតសម្រាប់និស្សិតអន្តរជាតិ ប្រសិនបើពួកគេមិនចូលចិត្តរបៀបរស់នៅ ក្នុងទីក្រុងធំៗ ផ្ទុយទៅវិញពួកគេអាចប្រើឱកាសនេះដើម្បីទាញយកអត្ថប្រយោជន៍ក្នុងការរៀននិងអនុវត្ត និយាយភាសាអង់គ្លេសរបស់ពួកគេជាមួយជនជាតិអូស្ត្រាលីផ្សេងទៀតដែលរស់នៅទីនេះផងដែរ។**

ទន្ទឹមនឹងនេះ ការធ្វើដំណើរទៅ និងមកពីទីក្រុងមែលប៊ិនក៏មានភាពងាយស្រួលផងដែរ ដូច្នេះហើយនិស្សិត អន្តរជាតិរបស់យើងក៏មានឱកាសទៅសួរសុខទុក្ខសាច់ញាតិ និងមិត្តភក្តិនៅទីក្រុងមែលប៊ិន ឬទាក់ទងជាមួយ សិស្សផ្សេងទៀតក្នុងអំឡុងពេលថ្ងៃឈប់សម្រាក និងចុងសប្តាហ៍។

ជារៀងរាល់ឆ្នាំ អនុវិទ្យាល័យ ឃើណៃយើងកំណត់ទទួលយកចំនួននិស្សិតអន្តរជាតិត្រឹមតែ ៤០ នាក់ប៉ុណ្ណោះ ដើម្បីធានានូវការមើលថែទាំដ៏ល្អបំផុតសម្រាប់និស្សិតអន្តរជាតិនីមួយៗ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ យើងបានទទួលស្វាគមន៍និស្សិតអន្តរជាតិជាច្រើន រួមមាននិស្សិតអន្តរជាតិមកពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ចិន អាល្លឺម៉ង់ ជប៉ុន្ន កូរ៉េ ឥណ្ឌូនេស៊ី ម៉ាល់តា ម៉ាឡេស៊ី ប៉ាពួញូហ្គីណេ និងវៀតណាមជាដើម។

យោងតាមបទសម្ភាសន៍ និស្សិតអន្តរជាតិរបស់យើងទាំងអស់បានទទួលបទពិសោធន៍សប្បាយរីករាយនិងពេលវេលា ដ៏អស្ចារ្យដែលមិនអាចបំភ្លេចបាន្នក្នុងអំឡុងពេលស្នាក់នៅរបស់ពួកគេជាមួយអនុវិទ្យាល័យ  ឃើណៃ។

គ្រប់និស្សិតអន្តរជាតិដែលបានបញ្ចប់ការសិក្សាពីអនុវិទ្យាល័យ ឃើណៃ បានចុះឈ្មោះបន្តការសិក្សារបស់ បានចុះឈ្មោះបន្តការសិក្សារបស់ពួកគេនៅក្នុងសាកលវិទ្យាល័យអូស្ត្រាលីល្បីៗ និងសាកលវិទ្យាល័យអន្តរជាតិ ល្បីៗជាច្រើន។ នៅខាងក្នុងនេះ រួមមានសាកលវិទ្យាល័យមែលប៊ិន (Melbourne University) សាកលវិទ្យាល័យ ម៉ូណាស (Monash University) សាកលវិទ្យាល័យដីហាបនៃចក្រភពអង់គ្លេស (Durham University) និង សាកលវិទ្យាល័យមីឈីហ្គែននៃសហរដ្ឋអាមេរិក (Michigan University) ។

នៅអនុវិទ្យាល័យឃើណៃ យើងមានកម្មវិធីជាច្រើនជាពិសេសសម្រាប់និស្សិតអន្តរជាតិរួមមាន:

- មជ្ឈមណ្ឌលសម្រាប់បង្ហាត់បង្រៀនភាសាអង់គ្លេស
- អ្នកសម្របសម្រួលនិស្សិតអន្តរជាតិចិន ជប៉ុន និងអាល្លឺម៉ង់ដែលមានបទពិសោធន៍ លើសពីនេះក៏មានបុគ្គលិក ផ្សេងទៀតដែលនិយាយភាសាផ្សេងៗទៀត
- ការចូលប្រើគ្រប់គ្រឿងបរិក្ខារទាំងអស់នៅសាកលវិទ្យាល័យ federation ក៏ដូចជាការបង្រៀនដោយ ឥតគិតថ្លៃពីនិស្សិតសាកលវិទ្យាល័យ
- មានជំរុំ និងដំណើរកំសាន្តទៅតាមរដ្ឋដោយឥតគិតថ្លៃ
- អាចប្រើប្រាស់ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកម្សាន្ត។

## អនុវិទ្យាល័យឃើណៃផ្តល់នូវកម្មវិធីសិក្សាដែលជួយជំរុញសិស្សឱ្យពូកែនិងបង្កើនជំនាញ

វិញ្ញាបនបត្រវិចតូរីយ៉ា នៃក្រសួងសិក្សានិងអប់រំ (VCE) គឺជាវិញ្ញាបនបត្រដែលសិស្សភាគច្រើនទទួលបាន នៅពេលបញ្ចប់ការសិក្សាអនុវិទ្យាល័យរបស់ពួកគេ។ VCE ផ្តល់នូវឱកាសសម្រាប់ការសិក្សាបន្ថែម ឬការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យផ្សេងៗទៀត ឬ TAFE ឬ ចូលទៅក្នុងការងារ។

នៅអនុវិទ្យាល័យឃើណៃ ការផ្តោតសំខាន់របស់យើងគឺផ្តល់ឱកាសសម្រាប់និស្សិតដើម្បីទទួលបានភាពជោគជ័យ នៅក្នុងការសិក្សាជាន់ខ្ពស់របស់ពួកគេ។ បរិវេណសាលារបស់យើងមានទីតាំងនៅក្នុងបរិវេណសាកលវិទ្យាល័យ Federation នៃក្រុង Gippsland

អនុវិទ្យាល័យរបស់យើងផ្តល់ជូននូវជម្រើសមុខវិជ្ជាជាច្រើនសម្រាប់សិស្ស VCE ដើម្បីជ្រើសរើសរួមមាន ផ្នែកនៃគណិតវិទ្យា ភាសា មនុស្សសាស្ត្រ សេដ្ឋកិច្ច វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសុខភាព សិល្បៈ និងបច្ចេកវិទ្យា។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ និស្សិតអន្តរជាតិនៅអនុវិទ្យាល័យឃើណៃបានសម្រេចនូវលទ្ធផលឆ្នើមក្នុងការប្រឡង VCE របស់ពួកគេ ដែលក្នុងនោះពួកគេទទួលបានពិន្ទុ (ATAR) ជាមធ្យមលើសពី 85 ហើយពិន្ទុខ្ពស់បំផុតដែលអាចធ្វើបានគឺ 99.95។

ចាប់ពីឆ្នាំ 2009 ដល់ឆ្នាំ 2021 និស្សិតអន្តរជាតិទាំងអស់បានបន្តការសិក្សាថ្នាក់ឧត្តមសិក្សារបស់ពួកគេ ហើយត្រូវបានទទួលយកដោយស្ថាកលវិទ្យាល័យផ្សេងទៀត ឬ TAFE ដែលក្នុងនោះពួកគេភាគច្រើនត្រូវ បានអនុញ្ញាតឱ្យចូលរៀននៅសកលវិទ្យាល័យល្បីៗនៅក្នុងប្រទេសអូស្ត្រាលី ក៏ដូចជាប្រទេសដទៃទៀតផងដែរ ។

អនុវិទ្យាល័យឃើណៃក៏មានមោទនភាពក្នុងការផ្តល់ជូនសិស្សានុសិស្សនូវឱកាសជាច្រើនដើម្បីស្វែងរកទេពកោសល្យច្នៃប្រឌិត និងអភិវឌ្ឍចំណង់ចំណូលចិត្តរបស់ពួកគេ។ ឱកាសទាំងអស់នេះគឺត្រូវបានផ្តល់ឱ្យតាមរយៈការចូល រួមក្នុងកម្មវិធីសិក្សាទាក់ទងទៅនឹងមុខវិជ្ជាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (VET) មួយចំនួន ដែលសិស្សានុសិស្ស ទទួលបានការបទពិសោធន៍ពិតៗដែលអាចប្រើប្រាស់បានក្នុងជីវិត ក្នុងផ្នែកដែលពួកគេមានចាប់អារម្មណ៍ទៅលើ។

ការចូលរួមក្នុងកម្មវិធី VET ជារឿយៗផ្តល់ឱកាសឱ្យសិស្សានុសិស្សនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ សិស្សានុសិស្សនៅពេលធ្វើការដាក់ពាក្យសុំការងារ ពីព្រោះពួកគេបានទទួលនូវបទពិសោធន៍និង ការបណ្តុះបណ្តាលនៅក្នុងវិស័យដែលពួកគេចាប់អារម្មណ៍រួចមកហើយ។





## អនុវិទ្យាល័យឃីណៃជាជម្រើសដ៏ល្អសម្រាប់កម្មវិធីសិក្សានិងសកម្មភាពផ្សេងៗក្រៅពីការសិក្សា

ម្បីតែសិស្សឆ្នាំទី 7 ដល់ 10 ក៏អាចមានឱកាសចូលរួមក្នុងកម្មវិធីសិក្សាកម្រិតខ្ពស់ដែលអនុញ្ញាតឱ្យពួកគេទទួល បានបទពិសោធន៍មួយដ៏ស៊ីជម្រៅ និងជួយពង្រឹងការគិតពិចារណារបស់ពួកគេ រួមទាំងការសិក្សាផ្នែកគណិតវិទ្យា ភាសាអង់គ្លេស វិទ្យាសាស្ត្រ និងមនុស្សសាស្ត្រ។ បទពិសោធន៍ទាំងនេះត្រូវបានសម្រេចដោយការអភិវឌ្ឍក្រមសីលធម៌ការងារដ៏ល្អមួយ ការអនុវត្តថ្មីៗ និងការប្រកួតប្រជែងគំនិតជាមួយសិស្សានុសិស្សផ្សេងទៀតក្នុង សកម្មភាពផ្សេងៗដែលនៅក្រៅការសិក្សា។

លើសពីនេះទៀត អនុវិទ្យាល័យឃីណៃក៏មានកម្មវិធីតន្ត្រីដែលផ្តល់ឱកាសឱ្យសិស្សានុសិស្សដើម្បីសិក្សា និងចូលរួមជាមួយសហគមន៍មួយដ៏រស់រវើក និងទាក់ទាញ។ អនុវិទ្យាល័យឃីណៃផងដែរក៏មានការផ្តល់ជូននូវតម្លៃ សិក្សាឧបករណ៍តន្ត្រីជាច្រើនប្រភេទរួមមាន ខ្យល់ឈើលង្ហិន ឧបករណ៍គោះ និងឧបករណ៍ខ្សែ។

នៅឆ្នាំទី 7 រាល់សិស្សានុសិស្សទាំងអស់នឹងចូលរួមកម្មវិធីសិក្សាថ្នាក់រៀនតន្ត្រី។ សិស្សទាំងអស់នឹងរៀនពីរបៀបអាន សួរសេរ និងលេងភ្លេង បន្ទាប់មកពួកគេអាចជ្រើសរើសបន្តថ្នាក់តន្ត្រីនៅឆ្នាំទី 9 និងទី 10 ដែលសិស្សនឹងបន្តអភិវឌ្ឍ ជំនាញតន្ត្រីកររបស់ពួកគេ។

កម្មវិធីសិក្សាផ្សេងទៀត រួមមានការធ្វើដំណើរទៅកសិដ្ឋានរបស់នាយកសាលា នេះអនុញ្ញាតឱ្យសិស្សទទួលបាន ទទួលបានការយល់ដឹងពីភូមិសាស្ត្រក្នុងតំបន់ដែលពួកគេកំពុងរស់នៅ ក៏ដូចជាយល់ពីការរំពឹងទុកអំពីសកម្មភាព ចូលរួមក្នុងអំឡុងពេលធ្វើដំណើរកម្សាន្តនិងថ្ងៃឈប់សម្រាករបស់សាលា។

ក្រៅពីនោះក៏មានក្រុមកីឡាមួយចំនួនដែលនិស្សិតអន្តរជាតិតែងតែបង្ហាញពីចំណាប់អារម្មណ៍ចង់ចូលរួមក្នុងការប្រកួតកីឡាផ្សេងៗ នេះរួមបញ្ចូលទាំងកីឡាជាច្រើនប្រភេទដូចជា បាល់ទាត់ បាល់បោះ វាយសី និងកីឡាផ្សេងៗជាច្រើន ទៀត។

## យើងផ្តោតសំខាន់លើសុខុមាលភាព និងគាំទ្រការសិក្សារបស់សិស្សានុសិស្សជានិច្ច

នៅអនុវិទ្យាល័យឃីណៃ យើងយល់ច្បាស់ណាស់ថាការជ្រើសរើសសាលារៀនមានសារៈសំខាន់ណាស់ ដើម្បីធានាបាននូវការអប់រំនិងសិក្សាមួយដ៏ល្អបំផុត។ យ៉ាងណាក៏ដោយ ពួកយើងក៏យល់ច្បាស់ថាបរិយាកាសសិក្សាក៏មានសារៈសំខាន់ចំពោះសិស្សផងដែរ ពីព្រោះពួកគេចង់បានកន្លែងសិក្សាមួយដែលមាន សុវត្ថិភាព និងពរពេញទៅដោយការគាំទ្រពីមិត្តភក្តិរបស់ពួកគេ បុគ្គលិក និងគ្រូទាំងអស់។

- សម្រាប់និស្សិតអន្តរជាតិទាំងអស់ ខាងសាលាមានផ្តល់ជូននូវ:
- ឯកសណ្ឋានសាលាដោយឥតគិតថ្លៃ
- ការស្នាក់នៅជាមួយក្រុមគ្រួសារដែលត្រូវបានបណ្តុះបណ្តាលយ៉ាងល្អក្នុងការជួយសិស្សឱ្យសម្របខ្លួននៃ
- របៀបរស់នៅរបស់ប្រទេសអូស្ត្រាលី
- ការណែនាំអំពីសាលារៀន និងតំបន់ជុំវិញដែលពួកគេស្នាក់នៅ
- កម្មវិធីទំនាក់ទំនងដើម្បីកសាងមិត្តភាព
- ការបង្រៀននិងផ្តល់ជំនួយបន្ថែមក្នុងការសិក្សានៅគ្រប់មុខវិជ្ជា
- ការបង្កើតក្រុមសិក្សា
- អាចទំនាក់ទំនងជាមួយបុគ្គលិក 24/7 ក្នុងករណីមានអាសន្ន។

នៅអនុវិទ្យាល័យឃីណៃ យើងយល់ពីភាពរំភើបរីករាយ និងតានតឹងដែលនិស្សិតអន្តរជាតិតែងតែជួបប្រទះ។ ម្យ៉ាងវិញទៀត យើងក៏យល់អំពីការរំពឹងទុក និងកង្វល់របស់ឪពុកម្តាយរបស់គ្រប់និស្សិតអន្តរជាតិដូច្នេះហើយបុគ្គលិក របស់យើងទាំងអស់ ព្រមទាំងគ្រូបង្រៀននឹងព្យាយាមអស់ពីសមត្ថភាពក្នុងការរួមដំណើរនេះ ដោយការជួយ

និងយកចិត្តទុកដាក់ខ្ពស់ដល់និស្សិតអន្តរជាតិរបស់យើង ដើម្បីធ្វើឱ្យការស្នាក់នៅរបស់ពួកគេនៅ អនុវិទ្យាល័យឃីណៃ ជាបទពិសោធន៍មួយដែលពួកគេមិនអាចបំភ្លេចបាន។

## ការជ្រើសរើសក្រុមគ្រួសារសម្រាប់ស្នាក់នៅជាមួយរបស់និស្សិតអន្តរជាតិ

នៅអនុវិទ្យាល័យឃីណៃ យើងយល់ពីនិស្សិតអន្តរជាតិទាំងអស់ដែលត្រូវរស់នៅឆ្ងាយពីផ្ទះ ដូច្នេះហើយយើងនឹង ប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ថាដូចជាពួកគេកំពុងរស់នៅផ្ទះរបស់ខ្លួនឯងផងដែរ។ ក្រុមគ្រួសារស្នាក់នៅទាំងនេះមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យការសិក្សា និងតាមដានសុខុមាលភាពរបស់សិស្ស ក្រៅម៉ោងសិក្សា ហើយពួកគេរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាលា និងតែងតែរាយការណ៍ពីកង្វល់ណាមួយ ទៅសាលា។

ទំនួលខុសរបស់គ្រប់ក្រុមគ្រួសារស្នាក់នៅជាមួយរួមមានការត្រួតពិនិត្យការសិក្សា និងតាមដានសុខុមាលភាព របស់សិស្សក្រៅម៉ោងសិក្សា បន្ថែមពីលើនោះក្រុមគ្រួសារស្នាក់នៅក៏រក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយខាង សាលាដើម្បីធ្វើការរាយការណ៍ពីទុក្ខកង្វល់ណាមួយដែលទាក់ទងទៅនឹងសិស្ស។ សាលារបស់យើងបាន រៀបចំនិងកំណត់សិស្សត្រឹមតែពីរនាក់ប៉ុណ្ណោះសម្រាប់ស្នាក់នៅក្នុងផ្ទះនីមួយៗ ដើម្បីធានាបាននូវការរស់នៅ

ដ៏សមរម្យនិងយកចិត្តទុកដាក់យ៉ាងល្អបំផុតពីក្រុមគ្រួសារស្នាក់នៅទាំងនោះ។

- ក្រុមគ្រួសារស្នាក់នៅទាំងនេះផ្តល់ជូនសិស្សនូវ៖
- កន្លែងរស់នៅប្រកបដោយសុវត្ថិភាព
- គ្រួសារដែលដែលបានទទួលការបណ្តុះបណ្តាលតាមស្តង់ដារអំពីសុវត្ថិភាពកុមារ
- បន្ទប់តែមួយដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់សិស្ស
- អាហារបីពេលក្នុងមួយថ្ងៃរយៈពេលប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងមានអាហារសម្រន់
- សម្ភារៈបរិក្ខាររួមមានគ្រែ ទូខោអាវ កន្សែង និងស្រោមគ្រែ
- ថ្លៃទឹកប្រើប្រាស់ រួមទាំងហ្គាស អគ្គិសនី កំដៅ និងថ្លៃទឹក ព្រមទាំងអ៊ីនធឺណិតផងដែរ
- សេវាសម្អាតកន្លែងរស់នៅរួម
- ការប្រើប្រាស់បន្ទប់រួមផ្សេងទៀតនៅក្នុងផ្ទះ
- បរិក្ខារសម្រាប់សិក្សាដូចជា តុ អំពូលសម្រាប់សិក្សា និងទូដាក់សៀវភៅជាដើម
- ការចូលរួមកម្មវិធីប្រជុំអំពីដំណើរការសិក្សារបស់សិស្សក្នុងនាមឪពុកម្តាយរបស់សិស្ស។

បន្ទាប់ពីនិស្សិតអន្តរជាតិត្រូវបានតាំងទីលំនៅក្នុងគ្រួសារស្នាក់នៅរបស់ពួកគេ អ្នកសម្របសម្រួលនិស្សិតអន្តរជាតិ តែងតែរក្សាទំនាក់ទំនងជាទៀងទាត់ជាមួយក្រុមគ្រួសារស្នាក់នៅទាំងនោះដើម្បីយល់ដឹងថានិស្សិតអន្តរជាតិគ្រប់ រូបត្រូវបានមើលថែយ៉ាងល្អពីគ្រួសារស្នាក់នៅជាមួយ។

## ទីតាំងល្អងាយស្រួលក្នុងការធ្វើដំណើរទៅនិងមក

អនុវិទ្យាល័យឃីណៃ មានទីតាំងនៅកណ្តាលក្រុង Gippsland ដ៏ស្រស់ស្អាតក្នុងរិចតូរីយ៉ា។ ការធ្វើដំណើរទៅ កាន់កណ្តាលទីក្រុងមែលប៊ើនដោយរថយន្តមានចំណាយប្រហែល 90 នាទី។ ការធ្វើដំណើរពី Gippsland

ទៅទីក្រុងមែលប៊ើន អ្នកក៏អាចជិះរថភ្លើង V/Line ដើម្បីទៅដល់ស្ថានីយ៍ Flinders Street នៅចំកណ្តាល ទីក្រុងមែលប៊ើន។

តំបន់ Gippsland គឺជាតំបន់ទេសចរណ៍ដ៏ល្បីល្បាញមួយក្នុងប្រទេសអូស្ត្រាលីជាមួយនឹងអាកាសធាតុដ៏បរិសុទ្ធនិង ទេសភាពធម្មជាតិយ៉ាងស្រស់ស្អាត។ កន្លែងកំសាន្តទាក់ទាញរួមមានឆ្នេរសមុទ្រដ៏ធំនិងបឹងធម្មជាតិសម្រាប់ ភ្ញៀវទេសចរដើម្បីមើលថ្ងៃលិចដ៏ស្រស់ស្អាត ព្រមទាំងមានកីឡាក្នុងទឹកដើម្បីលេងកំសាន្តនៅរដូវក្តៅ។ ដូចគ្នានេះដែរ ក្នុងរដូវរងារភ្ញៀវទេសចរក៏អាចទៅជិះស្គីលើភ្នំព្រិលនិងរមណីយដ្ឋាន ឬដើរលេងទៅតាមជួរភ្នំជាដើម។

ទីតាំងនៃសាលារបស់យើងផ្តល់ជូន៖

- ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីក្រុង Latrobe
- ស្ថិតនៅជិតមហាសមុទ្រ និងភ្នំ ប៉ុន្តែមានចម្ងាយតែរយៈពេល 90 នាទីពីទីក្រុងមែលប៊ិន
- ងាយស្រួលសម្រាប់និស្សិតអន្តរជាតិក្នុងការសម្របខ្លួនដើម្បីសិក្សានៅសាកលវិទ្យាល័យ Federation សាខា Gippsland នៅពេលដែលពួកគេបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យឃីណៃ។




> អនុវិទ្យា ល័យឃីណៃ ប្រៀ បបាន
> ដូចជាគ្រួ សារមួយសម្រា ប់ខ្ញុំ

## បទពិសោធន៍ផ្សេងៗ របស់អតីតសិស្សានុសិស្ស

យូស៊ីនលី (Yuxin Li) ជាអតីតសិស្សមកពីប្រទេសចិន ហើយបច្ចុប្បន្នគាត់កំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់នៅ សាកលវិទ្យាល័យដឺហាំបនៃចក្រភពអង់គ្លេស (Durham University) ។ គាត់បានចែករំលែកបទពិសោធន៍របស់គាត់ជាមួយយើង នៅក្នុងនោះគាត់បានលើកឡើងថា

□អនុវិទ្យាល័យឃីណៃប្រៀបបានដូចជាគ្រួសារមួយសម្រាប់ខ្ញុំ ពីព្រោះលោកគ្រូអ្នកគ្រូពួកគាត់បានយកចិត្តទុក ដាក់យ៉ាងខ្លាំងចំពោះខ្ញុំ។ រីឯវគ្គសិក្សាវិញក៏មានភាពប្លែកបែននិងខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធសាលារៀនរបស់ប្រទេសចិនផងដែរ។ ខ្ញុំអាចជ្រើសរើសមុខវិជ្ជាដែលខ្ញុំចាប់អារម្មណ៍ ដូចជាការសិក្សាផ្នែកច្បាប់ ដើម្បីបង្កើនបទពិសោធន៍សម្រាប់អាជីពនាពេលអនាគតរបស់ខ្ញុំ។□

ប៉េងហ្ស៊ូ ជៀន (Pengzuo Jian) ជាអតីតសិស្សមកពីប្រទេសចិនផងដែរ ហើយបច្ចុប្បន្នគាត់កំពុងសិក្សាបរិញ្ញាបត្រ ផ្នែកវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យមែលប៊ិន។ គាត់បានចែករំលែកបទពិសោធន៍របស់គាត់ជាមួយយើង នៅក្នុងនោះគាត់បានលើកឡើងថា

□នៅអនុវិទ្យាល័យឃីណៃ សិស្សមានក្តីសុបិន្តផ្សេងៗគ្នា ហើយសិស្សគ្រប់រូបតែងតែប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីសម្រេចក្តីសុបិនរបស់ពួកគេ។ បន្ថែមពីលើនោះទៀត អនុវិទ្យាល័យឃីណៃស្ថិតនៅទីតាំងតែមួយនៃសាកលវិទ្យាល័យ Federation ដូច្នេះខ្ញុំតែងតែទៅសិក្សានៅបណ្ណាល័យនៅសាកលវិទ្យាល័យ ជាមួយនិស្សិតសាកលវិទ្យាល័យធ្វើឱ្យខ្ញុំមានអារម្មណ៍ដូចជាខ្ញុំជាសិស្សម្នាក់ក្នុងចំណោមពួកគេដែរ។ ខណៈពេលដែលខ្ញុំកំពុងសិក្សានៅទីនោះ និស្សិតអន្តរជាតិត្រូវបានមើលថែយ៉ាងយកចិត្តទុក បន្ថែមពីនោះទៅទៀត អនុវិទ្យាល័យឃីណៃក៏ប្រារព្ធពិធីបុណ្យប្រពៃណីនៃប្រទេសផ្សេងៗសម្រាប់ឱ្យនិស្សិតអន្តរជាតិចូលរួម។ ម្យ៉ាងវិញទៀត រៀងរាល់ថ្ងៃព្រហស្បតិ៍ សាលារៀនកម្មង់តែងតែមុខម្ហូបអាហារចិនជូនសិស្សទាំងអស់ផងដែរ។ ជារួម ខ្ញុំនឹងប្រើប្រាស់ពេលវេលាដ៏មានតម្លៃរបស់ខ្ញុំដែលនៅសល់របស់ខ្ញុំនៅអនុវិទ្យាល័យឃីណៃឱ្យមានតម្លៃបំផុត។ បន្ទាប់ពីបទពិសោធន៍ដ៏អស្ចារ្យទាំងអស់នេះហើយ ខ្ញុំសង្ឃឹមថានឹងឃើញអ្នកនឹងពិចារណាដើម្បីបន្តការសិក្សា របស់អ្នកនៅអនុវិទ្យាល័យឃីណៃ។□



Kurnai College
PATHWAYS TO SUCCESS

# ទំនាក់ទំនងសាលា

អនុវិទ្យាល័យឃឺណៃ

អាស័យដ្ឋានសាលា: 53 Northways Road, Churchill, Victoria 3842

លេខទូរសព្ទទំនាក់ទំនង +61 3 5132 3800

អ្នកសម្របសម្រួលនិស្សិតអន្តរជាតិ - លោក James Yao និង លោកស្រី Linda Yin

អ៊ីមែល: international@education.vic.gov.au

គេហទំព័រ: www.study.vic.gov.au

VICTORIA
State Government
Australia

**Victorian Government Schools International Student Program**

80 Collins Street, Melbourne Victoria 3000, Australia

Tel: +61 3 7022 1000
Email: international@education.vic.gov.au
Web: www.study.vic.gov.au

Published by the International Education Division

Department of Education Melbourne January 2023

© State of Victoria (Department of Education) 2023

CRICOS Provider Name and Code: Department of Education, 00861K